មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន ម.ស.ម.ក

ភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨

## កាលបរិច្ឆេទសវនាការរបស់សកម្មជនមាតាធម្មជាតិកម្ពុជា ត្រូវបានកំណត់

*កាលបរិច្ឆេទ ៖* *ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨*
*ឈ្មោះ ៖* *ហ៊ិន វណ្ណៈ និង នីម គុននី*
*ប្រភេទនៃសកម្មជន ៖* *សកម្មជនផ្នែកបរិស្ថាន*
*ទីតាំង ៖* *ខេត្តកោះកុង*
*ប្រភេទនៃការគំរាមកំហែង ៖* *ផ្នែកច្បាប់*

សកម្មជនមាតាធម្មជាតិកម្ពុជា លោក ហ៊ិន វណ្ណៈ និង លោក នីម គុននី បានដឹងនូវថ្ងៃសវនាការរបស់ខ្លួន បន្ទាប់ពីស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ៤ ខែជាង ដោយរងការចោទប្រកាន់ពីបទ "ការរំលោភកម្មសិទ្ធិឯកជន" និង "ការញុះញង់ឲ្យប្រព្រឹត្តបទល្មើស" ក្នុងមាត្រា ៣០២ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

លោក ហ៊ិន វណ្ណៈ និង លោក នីម គុននី ត្រូវបានចាប់ខ្លួននៅលើឆ្នេរព្រែកខ្សាច់ ក្នុងខេត្តកោះកុង នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ដោយសារបានថតវីដេអូកប៉ាល់ពីរគ្រឿងដែលគេសង្ស័យថាកំពុងតែដឹកជញ្ជូនខ្សាច់ស៊ីលីកាដោយខុសច្បាប់សម្រាប់នាំចេញ។ អ្នកទាំងពីរត្រូវបានចាប់ខ្លួនបន្ទាប់ពីមានពាក្យបណ្តឹងមកពីក្រុមហ៊ុនអិលវ៉ាយភី ដែលជាក្រុមហ៊ុនរបស់សមាជិកព្រឹទ្ធសភា លោក លី យ៉ុងផាត់ ដែលពាក្យបណ្តឹងនេះកើតឡើងត្រឹមតែមួយថ្ងៃ បន្ទាប់ពីមាតាធម្មជាតិកម្ពុជា បានចេញផ្សាយខ្សែវីដេអូបង្ហាញពីភាពខុសគ្នានៃទិន្នន័យការនាំចេញរបស់រដ្ឋាភិបាល។[1]

ការស្នើសុំឲ្យនៅក្រៅឃុំរបស់ពួកគេត្រូវបានបដិសេធកាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧ ហើយពួកគេក៏ត្រូវបានដាក់ក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងពន្ធនាគារខេត្តកោះកុង អស់រយៈពេល ១៣៣ ថ្ងៃមកហើយនៅក្នុងស្ថានភាពដែលមិនសមប្រកប។[2]

សវនាការនេះនឹងចាប់ផ្តើមនៅម៉ោង ៨ព្រឹក នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ នៅសាលាដំបូងខេត្តកោះកុង។ ប្រសិនបើតុលាការសម្រេចថាមានទោស ពួកគេនឹងត្រូវប្រឈមនឹងការជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤ លានរៀល។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង អ្នកសម្របសម្រួលគម្រោង ការពារសេរីភាពមូលដ្ឋាន អ្នកស្រី សន រ៉ាមណា តាមរយៈទូរស័ព្ទលេខ៖ ០១៧ ៦៥៥ ៥៩១ និងអ៊ីមែល៖ ramanasorn@cchrcambodia.org។**

---

[1] សេន ដាវីដ "សកម្មជនមាតាធម្មជាតិត្រូវបានឃាត់ខ្លួន" ខ្មែរ ថាមស៍ (ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧) http://bit.ly/2m0jh2v សូមអានបន្ថែម៖ សេន ដាវីដ "សកម្មជនបរិស្ថានត្រូវបានចោទប្រកាន់" ខ្មែរ ថាមស៍ (ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧) http://bit.ly/2yVWYEd.

[2] សម្រាប់ព័ត៌មានបន្ថែម សូមអាន ៖ សេចក្តីប្រកាសព័ត៌មានរួម "អង្គការសង្គមស៊ីវិលស្នើឲ្យដោះលែងលោក ហ៊ិន វណ្ណៈ និង លោក នីម គុននី ជាសកម្មជនអង្គការមាតាធម្មជាតិនៅកម្ពុជា" (ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧) អាចអានបាន ៖ http://bit.ly/2BjEeOx